# បំភ្លឺបុណ្យ



២១៤.
៨៧

www.elibraryofcambodia.org

ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

២១៤.៨៧

# បំភ្លឺបុណ្យ



វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៦៩១៥/០៣

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

បុណ្យជាឆន្ទៈនាំអោយអ្នកធ្វើស្រលាញ់ពេញចិត្ត ចូលចិត្តធ្វើមិនចេះឆ្អែតស្កប់ស្កល់។ សព្វថ្ងៃនេះក្លាយទៅជាប្រពៃណី ចូលជ្រៅក្នុងមនោសញ្ចេតនា របស់ពួកសាសនិក ជិតជាប់ជានិច្ច ខានធ្វើមិនបាន ដូចបុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ កឋិន ផ្កាជាដើម ។

អត្ថាសូមគាំទ្រឆន្ទៈនេះទាំងស្រុង ព្រមទាំងរួមមតិ ជួយបំភ្លឺ អ្នកធ្វើបុណ្យ អោយភ្លឺស្វាងផងដែរ ។

បុណ្យ បើអ្នកធ្វើបានថ្នាក់ត្រឹមតែគោរពប្រពៃណីប៉ុណ្ណោះ បញ្ហាបុណ្យនៅតែជាបញ្ហាស្មុគស្មាញគ្មានទីបញ្ចប់អ្នកដឹកនាំពិធីបុណ្យប្រ ឈមមុខដោះស្រាយគ្រប់ពេលវេលា ដោយប្រមូលផ្តុំមតិគ្នាមិនទាន់ស្រប ។

ខ្លឹមសារនិងន័យរបស់បុណ្យ នៅក្នុងសៀវភៅនេះ ជាប្រទីបជួយបំភ្លឺចំពោះអ្នកពេញចិត្តធ្វើបានមួយចំនួន ។

- សូមព្រះពុទ្ធសាសនា រីកចម្រើនរុងរឿង ។
- សូមពិភពលោកស្ថិតនៅក្នុងសន្តិភាពជានិច្ចនិរន្តន៍ ។
- សូមរដ្ឋកម្ពុជាសម្បូររុងរឿង សុខក្សេមក្សាន្តជានិច្ច ។

ថ្ងៃទី ១៣ សីហា ព.ស ២៥៣៤ គ.ស ១៩៩០

ព្រះសង្ឃត្ថេរោ **អ៊ុម ស៊ុម**



www.budinst.gov.kh www.elibraryofcambodia.org

# ជីវប្រវត្តិសង្ខេបព្រះសង្ឃត្ថេរ អ៊ុម ស៊ុម

ព្រះសង្ឃត្ថេរ អ៊ុមស៊ុម កើតនៅថ្ងៃសុក្រ ១២ កើត ខែមាឃ ឆ្នាំមមែ ព.ស ២៤៦២ គ.ស ១៩១៩ ។ មាតាឈ្មោះ សុខ មី៖ បិតាឈ្មោះ មាស អ៊ុម នៅឃុំជិរោ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ អាយុ ១២ឆ្នាំ ទៅរៀនសូត្រ នៅវត្តជីរោ អាយុ ១៦ ឆ្នាំ បួសជាសាមណេរ អាយុ២១ឆ្នាំ បួសជាភិក្ខុ។ បួសហើយនៅរៀនវិបស្សនា ធុរៈ ១ឆ្នាំ ទើបចេញទៅរៀន គន្ថធុរៈដំបូងនៅវត្តកោះគល់ បន្ទាប់មកនៅវត្តកណ្តាល កោះសូទិនខេត្តកំពង់ចាម បន្ទាប់ទៀតនៅវត្តសារាវ័ន្តតេជោ រដ្ឋធានីភ្នំពេញ ។ បានប្រលងចូលរៀនជាប់សាលាបាលីជាន់ខ្ពស់ នៅឆ្នាំ ១៩៤៨។ បានប្រលងចូលរៀនជាប់ឱប្ឋម សាលាបាលីជាន់ខ្ពស់ នៅឆ្នាំ ១៩៥១ ។ បានធ្វើអាចារ្យ បង្រៀនបាលីនៅសាលាបាលីរង វត្តសារាវ័នតេជោ វត្តសំពៅមាស វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ វត្តជិរោ ខេត្តកំពង់ចាម។ បានចូលធ្វើក្រុមជំនុំព្រះត្រៃបិដក ឆ្នាំ១៩៥៥។ បានធ្វើព្រះគ្រូបាឡាត់ ភទ្ទបាល នៅវត្តកែវព្រះភ្លើង ។ បានធ្វើគ្រូវិន័យធរ ធ្វើគ្រូសូត្រជាប់ឆ្នោតនៅវត្តសារាវន្តតេជោភ្នំពេញ។ បានធ្វើមន្ត្រីសង្ឃ ជាន់ខ្ពស់ ព្រះសាសនមុនីរាជាគណៈថ្នាក់ទី២។



www.budinst.gov.kh www.elibraryofcambodia.org

បានធ្វើប្រធានធម្មទូត នៃ ពុទ្ធិកសមាគមកម្ពុជរដ្ឋ។ នៅឆ្នាំ១៩៧៥ត្រូវសឹកចាកភេទ មកជាគ្រហស្ថ ដោយគេបង្ខំ ។ នៅឆ្នាំ ១៩៨០ បានបួសឡើងវិញ ដោយរណសិរ្ស សាមគ្គី សង្គ្រោះជាតិកម្ពុជា ឧបត្ថម្ភ។ បានទទួលតួនាទីដឹកនាំគ្រប់គ្រងធម៌វិន័យ ព្រះពុទ្ធសាសនា ទូទាំងប្រទេសកម្ពុជា។

បានធ្វើប្រធានផ្សព្វផ្សាយព្រះពុទ្ធសាសនា :

- បោះពុម្ពសៀវភៅធម៌វិន័យផ្សេងៗ
- ផ្សព្វផ្សាយសំលេងធម៌តាមវិទ្យុ
- ផ្សព្វផ្សាយសំលេងធម៌ និងរូបភាពតាមទូរទស្សន៍ ។

សព្វថ្ងៃជាមេគណក្រុងភ្នំពេញ។



www.budinst.gov.kh www.elibraryofcambodia.org

# បំភ្លឺបុណ្យ

**អតិត្ថវេថ កល្យាណេ ឃាឃា ចិត្តំ និវារយេ**

**ទន្ធំ ហិ ករតោ បុញ្ញំ ឃាបស្មឹ មេតី មនោ ។**

បុរសប្រុសស្រី គប្បីប្រញាប់ប្រញាល់ធ្វើនូវកល្យាណកម្ម (បុណ្យទាំងឡាយ) គប្បីរាំងស្កាត់ ចិត្តចាកបាប ព្រោះថាបុណ្យ កាលណា គេយឺតយូរក្រធ្វើ ចិត្តជាតួបុណ្យ រមែងតែត្រេកអរ ចំពោះបាប ។

ពុទ្ធភាសិត ដែលលើកឡើងទាំងស្រុងនេះ គ្រាន់តែជាគោលធម៌សម្រាប់ជាមេគំនិត ត្រិះរិះពិចារណា ប្រមូលផ្ដុំចងក្រងលើកឡើង បំភ្លឺ អំពីបញ្ហាបុណ្យ និងបញ្ហាធ្វើពិធីបុណ្យផ្សេងៗ ប៉ុណ្ណោះ រួចហើយសឹមធ្វើ អត្ថាធិប្បាយ ពុទ្ធភាសិតខាងលើ។

មុនដំបូង យើងគួរចង់ដឹងថា :

១- អ្វីទៅបុណ្យ ?

២- អ្វីជាតួបុណ្យ ?

៣- បុណ្យប្រែដូចម្ដេច ?

៤- អ្វីជាឈ្មោះបុណ្យ ?

៥- អ្វីខ្លះជាអានិសង្ស របស់បុណ្យ ?

៦- តាមលទ្ធិព្រះពុទសាសនា គេធ្វើបុណ្យដើម្បីអ្វី ?

៧- ផ្លូវចិត្តជាបុណ្យ គេកត់សំគាល់យ៉ាងណាខ្លះ ?

## ១- អ្វីទៅបុណ្យ

សភាវៈដែលហាមឃាត់ចិត្តចាកបាបផ្សេងៗ បញ្ឈប់ចិត្តដែលអោយត្រេកត្រអាលចំពោះបាប បំភ្លេចអារម្មណ៍បាបចាស់ចោលអោយអស់ ធ្វើចិត្តអោយឃ្លាតផុតចាកបាប អកុសលថ្មី រួចហើយ បំពេញបុណ្យ កុសល ជាជំនួយវិញ្ញាណ កុំអោយទំនេរដើម្បីបង្វែរចិត្តអោយងាកមក ត្រេកត្រអាល



www.budinst.gov.kh www.elibraryofcambodia.org

លុះមកដល់ពុទ្ធកាល នៃព្រះសក្យមុនីគោត្តមបរមគ្រូនៃយើង ចុះមកកើតក្នុងមនុស្សលោក បានជាស្តេច១ព្រះអង្គ ក្នុងជម្ពូទ្វីបព្រះនាម ព្រះបាទចណ្ឌប្បជោត ទ្រង់មានយាកជំនិះ សេះ ដំរី សុទ្ធតែលឿនៗ ធ្វើ ដំណើរបាន១២០ យោជន៍ក្នុង១ថ្ងៃ ទ្រង់មានកម្លាំងខ្លាំង អំណាចរុងរឿង ដូចព្រះអាទិត្យរះចែងចាំងកណ្តាលនភាល័យ។

នេះជាអានិសង្សនៃកាយវិការ ដែលកំរើកដៃជើងធ្វើការ កុសលដោយចិត្តជ្រះថ្លា។

បុណ្យដែលគេធ្វើដោយផ្លូវវាចា ហៅថាវិចីវិការ គឺកម្រើកវាចា ធ្វើ កុសលផ្សេងៗ មានបញ្ចេញសម្លេងសូត្រធម៌ នមស្ការព្រះរតនៈត្រៃយ៍ និងសូត្រអោយគេស្តាប់ ឬប្រកាសឃោសនា បបួលគេអោយចូលរួមធ្វើកុសល ផ្សេងៗ មានធ្វើទានស្តាប់ធម៌ ទេសនា សមាទានសីល ជាដើម។ ដូចរឿងឃោសិតសេដ្ឋី ជាឧទាហរណ៍ សូមនាំរឿងនេះ ដោយសង្ខេបមក សំដែងដូចតទៅ ។

ក្នុងសម័យមុនពុទ្ធកាល នៃព្រះសក្យមុនីគោត្តម ជាអម្ចាស់យើង នេះ កាលនោះមានបុរសកំសត់ម្នាក់ ស្វែងរកអាហារក្នុងពេលដែលស្រុក កើតទុរភិក្ស គឺអត់បាយដោយអស់កម្លាំងពេក វេលាទៀបនឹងស្លាប់ គាត់ដេកសម្លឹងមើលមេឆ្កែដែលសេដ្ឋីម្នាក់គេអោយវាស៊ីបាយដោយភាជន៍ប្រាក់ ក៏នឹកស្ញើចក្នុងចិត្តគិតចង់កើតជាឆ្កែដ៏មានភ័ព្វ បានអាហារឆ្ងាញ់ៗ បរិភោគ លុះស្លាប់ទៅទៅកើតជាកូនឆ្កែនោះ សេដ្ឋីក៏ស្រលាញ់កូនឆ្កែ នោះណាស់ ទៅណាមកណាតែងយកទៅតាមខ្លួន។ សេដ្ឋីនោះជាអ្នករាប់អាន ព្រះបច្ចេកពុទ្ធ១ព្រះអង្គ ដែលមានអាស្រមនៅក្នុងព្រៃមួយក្បែរភូមិ របស់ខ្លួន ។ វេលានោះសេដ្ឋីបាន នាំកូនឆ្កែនោះទៅពីល្ងាច និមន្តព្រះបច្ចេកពុទ្ធមក ឆាន់ក្នុងផ្ទះខ្លួនក្នុងវេលាព្រឹកថ្ងៃស្អែក។ សេដ្ឋីនិមន្ត ហើយ ទូលព្រះបច្ចេកពុទ្ធថា « ព្រឹកស្អែក ខ្ញុំព្រះករុណានឹងប្រើកូនឆ្កែអោយមកនាំដំណើរព្រះអង្គទៅផ្ទះខ្ញុំព្រះករុណា » សូមព្រះអង្គនិមន្តតាមសញ្ញា ដែលកូនឆ្កែនេះនាំព្រះអង្គចុះ ។


www.budinst.gov.kh www.elibraryofcambodia.org

ដល់ព្រឹកឡើងសេដ្ឋីប្រាប់កូនក្ដៃអោយទៅនិមន្តព្រះអង្គ។ កូនក្ដៃនោះពិតមែនមិនចេះនិយាយភាសាមនុស្ស តែមានគំនិតប្រាជ្ញាវាងវៃ អាចស្ដាប់ដឹងសេចក្ដីសព្វគ្រប់បាន។ កាលសេដ្ឋីប្រើហើយ កូនក្ដៃនេះក៏រត់ទៅតាម ផ្លូវតំរង់ទៅ អាស្រមរបស់ព្រះបច្ចេកពុទ្ធ។ ពេលរត់ទៅតាម ផ្លូវកូនក្ដៃនោះ វាស្រែកព្រះខ្លាំងៗ ដេញសត្វនានាតាមព្រៃស៊ុបទ្រុប និងតាមដំបូកដែល នៅក្បែរផ្លូវ នោះចេញអស់ ដើម្បីកុំអោយវាចឹកខាំ ព្រះបច្ចេកពុទ្ធ។ លុះវារត់ទៅដល់អាស្រម វាឈរព្រុះខ្លាំងៗ នៅមុខអាស្រមជាសញ្ញានិមន្តព្រះអង្គ។ ព្រះបច្ចេកពុទ្ធឮសូរសំលេងព្រុះក៏ជ្រាប ថា កូនក្ដៃនិមន្តហើយ ក៏ព្រះអង្គរៀបចំឃ្លុំចីពរប្រដាប់ដោយបាត្រ និមន្តតាមក្រោយកូនក្ដៃ ទៅកាន់ផ្ទះសេដ្ឋី។ លុះដល់ផ្លូវបែកជាពីរ ព្រះអង្គចង់ដឹងគំនិតកូនក្ដៃ ក៏ធ្វើជានិមន្តតាមផ្លូវ១ដែលខុសពីផ្លូវទៅផ្ទះសេដ្ឋី។ កូនក្ដៃវាឃើញដូច្នោះ វាស្ទុះទៅទាញជាយស្បង់ បំបែរព្រះអង្គ អោយមកខាងផ្លូវត្រូវ។ ដល់ផ្លូវជាលំដាប់មក ព្រះអង្គធ្វើដូច្នោះទៀត កូនក្ដៃក៏ទាញស្បង់ទៀតទាល់តែរហែកជាយស្បង់។ លុះព្រះបច្ចេកពុទ្ធនិមន្តមកដល់ផ្ទះ សេដ្ឋីសួររឿងរហែកស្បង់ ព្រះអង្គប្រាប់តាមដំណើរនោះសព្វគ្រប់ សេដ្ឋីក៏ចាត់ចែងដេរជាស្បង់ ហើយនិមន្តឆាន់ដោយរីករាយ។ ឆាន់ហើយព្រះអង្គធ្វើអនុមោទនា រួចលាសេដ្ឋីត្រលប់ទៅអាស្រមវិញ។

កាលព្រះបច្ចេកពុទ្ធត្រលប់មកវិញ កូនក្ដៃតាមជូនទៅដែរ ដល់ផុត ពីភូមិទៅ ព្រះបច្ចេកពុទ្ធហោះឡើងទៅលើអាកាស។ វេលាព្រះអង្គហោះឡើង កូនក្ដៃក្រលេកមើល មានចិត្តស្រងេះស្រងោច អាល័យព្រះអង្គ ដរាបដល់បែកទ្រូងស្លាប់ក្នុងពេលនោះទៅ បានទៅកើតជាទេវបុត្រ នៅឋាន ត្រៃត្រឹង្ស ទេវលោក។

ដោយអានុភាពនៃស្រែកព្រុះនិមន្តព្រះបច្ចេកពុទ្ធ ទេវបុត្រនោះកើតមានសំលេង គងរំពងខ្លាំងជាងទេវបុត្រដទៃ គេអោយឈ្មោះថា ឃោសកទេវបុត្រ សោយសុខក្នុងទេវលោកអស់១ពុទ្ធន្តរ (ចន្លោះព្រះពុទ្ធ១អង្គ)។


www.budinst.gov.kh www.elibraryofcambodia.org

បុណ្យដែលគេធ្វើតាមផ្លូវចិត្ត ហៅថាធ្វើដោយមនោវិការ គឺកម្រើកចិត្ត នឹកគិតដល់ការកុសលផ្សេងៗ មានជ្រះថ្លានឹករលឹកដល់គុណព្រះរតនត្រៃយ ជាដើម ដែលបានជួបប្រទះឃើញដូចរឿង មដ្ឋកុណ្ឌលី ទេវបុត្រ។ សូមនាំរឿងនេះដោយសង្ខេបមកសំដែងដូចតទៅ :

កាលព្រះសម្ពុទ្ធ ទ្រង់គង់នៅវត្តជេតពន់ ទៀបក្រុងសាវត្ថី មានព្រាហ្មណ៍ម្នាក់ ជាមនុស្សកំណាញ់ មិនដែលបានធ្វើអ្វីតិចតួច ដល់អ្នកណាសោះ ទើបអ្នកស្រុកហៅថាអទិន្នបុព្វកៈ។ ព្រាហ្មណ៍នោះមានកូនប្រុសម្នាក់ ឈ្មោះមដ្ឋកុណ្ឌលីព្រោះគាត់អារជុំមាសខ្លួនគាត់ ខាត់អោយរលីង ធ្វើកុណ្ឌលអោយកូនពាក់។ កូននោះអាយុ១៦ឆ្នាំ មានជំងឺឈឺជាទំងន់។ អទិន្នបុព្វកៈព្រាហ្មណ៍ មិនហ៊ានទុកកូននៅល្វែងផ្ទះខាងក្នុង ខ្លាចញាតិ សន្ដានគេចូលទៅសួរកូនហើយឃើញសម្បត្តិទ្រព្យ គេសុំគាត់ក៏យកកូន មកដាក់អោយដេកនៅតាកខាងក្រៅផ្ទះ ។

មដ្ឋកុណលីមាណពជាកូនគិតថា «ឪពុកអញគាត់កំណាញ់ណាស់ នៅផ្ទះជិតវត្តជេតពន់ តែគាត់មិនដែលនិមន្ត ព្រះសង្ឃឆាន់ មិនដែល ដាក់បាត្រព្រះពុទ្ធឬព្រះសង្ឃមួយវែកសោះ ទាំងខ្លួនអញក៏គាត់មិនអោយ ទៅវត្តស្ដាប់ទេសនា គោរព ប្រណិប័តន៍ព្រះពុទ្ធនឹងព្រះសង្ឃសោះ ឥលូវខ្លួនអញឈឺធ្ងន់ក្រោកមិនរួចជិតដល់មរណៈទៅហើយ ធ្វើម្ដេចនឹងឃើញ ព្រះពុទ្ធជាម្ចាស់ ? »។ ពេលគិតនោះ មដ្ឋកុណ្ឌលី មាណពដេកបែរមុខទៅ ក្នុងផ្ទះស្រាប់តែព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ប្រមើលមើលឧបនិស្ស័យ សត្វទ្រង់ជ្រាបថា មដ្ឋកុណ្ឌលី មាណពឈឺទៀបស្លាប់ ព្រះអង្គក៏យាងទៅ ឈរនៅមុខផ្ទះ ទ្រង់បញ្ចេញព្រះឆព្វណ្ណរង្សី ៦ ពណ៌ចាំងភ្លែតៗ ទៅត្រង់ទីដែលមាណពដេក »។ មាណពឃើញព្រះឆព្វណ្ណរង្សី ក៏ងាកមក ក្រៅផ្ទះ បានឃើញព្រះអង្គ ក៏មានបីតិ ប្រាមោជ្ជត្រេកអរឥតឧបមា នឹកថា «ព្រះអង្គមកប្រោសខ្ញុំ ។ ក្រោកពុំរួចទេ សូមថ្វាយបង្គំ ព្រះអង្គតែដោយចិត្ត» ហើយក៏ធ្វើ


www.budinst.gov.kh www.elibraryofcambodia.org

មរណកាលទៅ បានទៅកើតជាទេវបុត្ត ក្នុងឋានត្រៃត្រឹង្ស សួគ៌ មានអប្សរាព ប៉ុនទេវបុត្ត ទាំងពួងដែលកើត ១៦ឆ្នាំ ក្រលេកមើលខ្លួនប្រាណឃើញថាខ្លួនមក កើតក្នុងទេវលោក ហើយមើលមក មនុស្ស លោកឃើញសាកសព របស់ខ្លួន គេកំពុងនាំយកទៅធ្វើឈាបនកិច្ចក្នុងទី ប៉ាឆា។ វេលាធ្វើឈាបនកិច្ចហើយ អទិន្នបុព្វកៈព្រាហ្មណ៍ តែងទៅ យំសោកបោកខ្លួន នៅទីប៉ាឆាជារៀងរាល់ថ្ងៃ។ ថ្ងៃមួយព្រាហ្មណ៍កំពុងតែយំកន្ទក់កន្ទេញ មដ្ឋកុណ្ឌលីទេវបុត្តក៏ចុះ មកជាមកជាមដ្ឋកុណ្ឌលី មាណព យំសោកក្នុងទីជិតគ្នានោះដែរ។

អទិន្នបុព្វកៈឃើញដូច្នោះក៏ងាកមកសួរថា «អ្នកជានរណា ?» មដ្ឋកុណ្ឌលីទេវបុត្ត ឆ្លើយថា «ខ្ញុំជាកូនរបស់អ្នកដែលស្លាប់ហើយទៅកើតជាទេវបុត្រនៅឋានត្រៃត្រឹង្ស ទេវលោក»។

- អ្នកគ្មានធ្វើបុណ្យអ្វីសោះ ម្តេចទៅកើតជាទេវបុត្រនៅឋានសួគ៌បាន ?

- ខ្ញុំគ្រាន់តែនឹកថ្វាយបង្គំ ព្រះពុទ្ធតែក្នុងចិត្ត នៅពេលដែលខ្ញុំទៀបស្លាប់ប៉ុណ្ណោះ ស្លាប់ទៅក៏បានទៅកើតក្នុងឋានសួគ៌។

- បើទៅកើតក្នុងឋានសួគ៌ហើយ ម្តេចក៏មកយំធ្វើអ្វី ?

- បានជាខ្ញុំមកយំ ព្រោះកង់រថរបស់ខ្ញុំបាត់ម្ខាង ខ្ញុំមកសុំវង់ព្រះ អាទិត្យដែលកំពុងរះនៅលើអាកាសនោះ ធ្វើជាកង់រថរបស់ខ្ញុំជំនួសកង់រថដែលបាត់ទៅ។

- អ្នកយំចង់បានវត្ថុដែលមិនគួរបាន ដូច្នេះមានតែអ្នកជាមនុស្ស វិកលចរិត។

- បើថាខ្ញុំយំចង់បានវង់ព្រះអាទិត្យ ដែលមានវង់មូលក្រឡង់មើលឃើញជាក់នឹងភ្នែកលាំងៗ ជាមនុស្សវិកលចរិត ខ្លួនអ្នកជាឪពុក យំចង់បានកូនដែលស្លាប់បាត់បង់រូបរាងទៅ ហើយនេះជាមនុស្សវិកលចរិកជាងខ្ញុំទៅទៀត មិនមែនឬ ?

អទិន្នបុព្វកៈ ព្រាហ្មណ៍ទាល់ប្រាជ្ញក៏លែងយំ ហើយគិតថា «ចាំអញ



www.budinst.gov.kh www.elibraryofcambodia.org

ទៅសួរព្រះសមណគោតមមើល តើមនុស្សគ្មានធ្វើទានអ្វីសោះ គ្រាន់តែនឹកថ្វាយបង្គំព្រះពុទ្ធ តែក្នុងចិត្តប៉ុណ្ណោះ បានទៅកើតជាទេវបុត្រក្នុងឋានសួគ៌ទេវលោកមែនឬ? បើមានមែនអញនឹងជឿ កាន់ព្រះពុទ្ធសាសនាតទៅ »។

លំដាប់ពីនោះ អទិន្នបុព្វកៈ ព្រាហ្មណ៍ចូលទៅកាន់វត្តជេតពនឈរ សួរព្រះដ៏មានបុណ្យថា «មនុស្សគ្មានធ្វើបុណ្យអ្វីសោះគ្រាន់តែនឹកថ្វាយបង្គំ ព្រះពុទ្ធតែក្នុងចិត្តតែប៉ុណ្ណោះ តើបានទៅកើតជាទេវបុត្រក្នុងឋានសួគ៌ មែនឬ?»

ព្រះអង្គឆ្លើយថា «ចាំអ្នកមកសួរតថាគតធ្វើអ្វីទៀត បើព្រឹកមិញអ្នកបានឃើញជាក់នឹងភ្នែក នូវមដ្ឋកុណ្ឌលី ជាកូនអ្នកដែលទៅកើតជាទេវបុត្រ នៅឋានសួគ៌ចុះមកជួបនឹងអ្នក នៅទីប៉ាឆា បានសួរដេញដោលគ្នាសព្វគ្រប់ស្រាប់ទៅហើយ »។

ព្រាហ្មណ៍នឹកស្ញើចក្នុងចិត្តថា «ឱ! ព្រះពុទ្ធព្រះអង្គគង់នៅឯវត្តជេតពន់ឯណោះ ម្ដេចក៏ទ្រង់ជ្រាបសព្វគ្រប់ម្លេះ ! ការនេះច្បាស់ជាព្រះអង្គជាព្រះអរហន្ត មានព្រះញាណទិព្វមែនហើយ បានជាទ្រង់ជ្រាប » ហើយព្រាហ្មណ៍ក៏ជ្រះថ្លា បានយកព្រះរតនៈត្រៃយ៍ជាទីពឹង ហើយធ្វើទាន រក្សាសីលក្នុងព្រះពុទ្ធសាសនាតទៅ ។

៤- អ្វីជាឈ្មោះរបស់បុណ្យ?

សេចក្ដីសុខជាឈ្មោះរបស់បុណ្យ ពីព្រោះជាលទ្ធផលកើតមកពីធ្វើ ចិត្តអោយស្អាត ចាកកិលេស ជាគ្រឿងសៅហ្មងស្មុគស្មាញនាំអោយមាន ភ័យផ្សេងៗ មានលោភៈ ទោសៈ មោហៈ ជាដើម អាទិ៍ ដូចពុទ្ធភាសិត ត្រាស់ថា មា ភិក្ខវេ បុញ្ញានំ ភយិត្ថ សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំ បុញ្ញានំ ម្នាលភិក្ខុ (អ្នកឃើញភ័យក្នុងសំសារវដ្ដទាំងឡាយ) អ្នកទាំងឡាយ កុំខ្លាចបុណ្យអោយសោះ ពីព្រោះពាក្យថាបុណ្យ គឺជាឈ្មោះ នៃ សេចក្ដីសុខទេតើ ។

ន័យនោះគួរយល់ថា ការធ្វើបុណ្យអ្វីមួយ ពីព្រោះតែចង់បានសុខ បើបុណ្យ ជាឈ្មោះនៃសេចក្ដីសុខស្រេចទៅហើយ អ្នកធ្វើបុណ្យទាំងឡាយ


www.budinst.gov.kh www.elibraryofcambodia.org

គាប្បីខិតខំសំអាតកាយ (កាយវិសោចេយ្យ) សំអាតវាចា (វចីវិសោ ចេយ្យ) សំអាតចិត្ត (មនោវិសោចេយ្យ) តែមួយយ៉ាងប៉ុណ្ណោះ ដើម្បីរង់ចាំទទួលបុណ្យគឺ សេចក្ដីសុខមិនគួរភ័យខ្លាច ឬព្រួយបារម្ភពីអ្វីផ្សេងទៀតអោយ សោះ។ បុគ្គលខ្លះមានទ្រព្យសម្បត្តិច្រើនល្មមពេក មានសទ្ធាជ្រះថ្លាធ្វើបុណ្យផ្សេងៗ មានបុណ្យផ្កា បុណ្យកឋិនជាដើម ចាប់ផ្ដើមធ្វើឡើងមាន ភ័យព្រួយបារម្ភទុកជាមុនជានិច្ច គឺភ័យខ្លាចក្រែង :

១- បានបច្ច័យសង្ហត់ត្រៃយ៍តិច

២- រៀបចំទទួលភ្ញៀវ មិនរាក់ទាក់មិនសមរម្យ

៣- គេរពញាតិធម៌មិនដិតដល់

៤- ភោជនាហារទទួលភ្ញៀវ ក្រែងមិនឆ្ងាញ់ពិសា

៥- ភ្ញៀវអ្នកចូលបុណ្យ ខ្លះចូលតិចក្រែងគេអន់ចិត្ត មិនល្មម ដល់ទឹកចិត្តគេទទួល ខ្លាចគេនិយាយដើម ឬមិនសូវបានបុណ្យ។

៦- និមន្តលោកទេសនា ក្រែងមិនពិរោះ ពិរោះហើយខ្លាចក្រែងបច្ច័យបូជាធម៌ បានតិចតួចខ្មាសគេ ឬមិនសមដល់បុណ្យសក្តិ ធម្មកឋិនអ្នកទេសនា ។ល។

បើគេមានគំនិតតែយ៉ាងនេះ គេបោះបង់ចោលលែងពឹងផ្អែកលើ បញ្ញារបស់ខ្លួន ដឹកនាំពិធីបុណ្យចាត់ចែង អស់ស្មារតីស្វែងរក ខុសត្រូវ ខាតចំណេញក្នុងមុខចំណាយទ្រព្យសម្បត្តិធ្វើបុណ្យបានច្រើន ឬតិចយ៉ាង ណាហើយ។ ម្ល៉ោះហើយទើបគេធ្វើបុណ្យម្ដងៗ គេមិនចាប់អារម្មណ៍ លើលក្ខណៈរបស់បុណ្យ៣យ៉ាងប៉ុន្មានទេ គឺ :

១- បសាទៈ សេចក្ដីជ្រះថ្លា

២- សំវេគៈ សេចក្ដីសង្វេគ តក់ស្លុត

៣- គេសុចរិតា ប្រព្រឹត្តិ សុចរិតទាំង៣។ គេរវល់តែរឿងភ័យស្លន់ស្លោ អំពាវនាវរកគេឯងអោយជួយ ប្រកាសប្រាប់គេថា «ខ្ញុំព្រួយចិត្ត ណាស់!


www.budinst.gov.kh www.elibraryofcambodia.org

ធ្វើបុណ្យម្តងនេះមិនដឹងជាយ៉ាងណាទេ លោតែបានបច្ច័យតិច តួច ខ្ញុំខ្មាស គេងាប់ហើយ មិនដឹងយកមុខទៅទុកឯណាទេ »។ល។ ចំណែកខាងប្រភព បុណ្យ មូលហេតុបុណ្យ តួបុណ្យចេញពីណា ហើយជា អ្វីទៀតនោះ គេបោះបង់ចោលអស់ លែងចាប់អារម្មណ៍ នឹកគិតខ្វល់ខ្វាយ ដោះស្រាយតែអំពីរឿងដែលឥតប្រយោជន៍ខាងលើ ។

ចូរអ្នកធ្វើបុណ្យទាំងឡាយ ពិចារណាមើល ព្រះពុទ្ធនិវាទ ខាងក្រោមនេះ

**មាវមញ្ញេថ ពុញ្ញស្ស ន មន្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**
**បូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។**

បុគ្គលមិនគួរមើលងាយបុណ្យថា បុណ្យមានប្រមាណតិច នឹងមិនអោយផលឡើយ ស្លប្បីក្អមទឹកដែលគេបើកតម្រប់ចំហបាន យ៉ាងណា មិញជនអ្នកមានប្រាជ្ញ គេសន្សំបុណ្យ ម្តងបន្តិចៗ យូរទៅតង់ពេញហប្ញទ័យដោយ[illegible]ណ្យបាន ក៏យ៉ាងនោះដែរ។

មានអ្នកខ្លះ មិនបានស្រាវជ្រាវ យល់ដោយស្មានយកពាក្យ បុណ្យ ប្រែថា «ពេញ» ទៅវិញ ប្រហែលជាគេស្មានថា «បុណ្យ» មកពីបូរ-ធាតុដើមគេប្រែថា «ពេញ» ? លុះប្រែរួចហើយ ថែមទាំងអធិប្បាយ[illegible]ញែកនូវពាក្យថា «ពេញ» គឺពេញដោយមានពួក ពុទ្ធបរិស័ទមកធ្វើ[illegible]ណ្យ ពេញវត្ត ពេញផ្ទះ ពេញរោងបុណ្យ ចំណែកបាយ សម្ល ផ្លែឈើ នំចំណីពេញចាន ពេញតុ ពេញថាស ។ល។ ទៀតផង។

តាមការពិត «បុណ្យ» ពុំមែនជារឿងពេញ ឬរឿងអ្វីដទៃផ្សេងទេ ប៉ុន្តែជារឿងអស់បន្ទិលសៅហ្មង ស្អាតរលីងធេងទេតើ ! គឺធ្វើអោយអស់កិលេស មានលោភៈ ទោសៈ មោហៈ មច្ឆរិយៈ ជាដើម ដែលជាគ្រឿងធ្វើចិត្ត


www.budinst.gov.kh www.elibraryofcambodia.org

អោយ កករល្អក់ សៅហ្មង ជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ អោយទៅជាចិត្ត ស្អាតរលីង មានពន្លឺភ្លឺថ្លា ដូចប្រក្រតីដើមឡើងវិញ។ ពីព្រោះចិត្ត កាលដើម ឡើយជា ធម្មជាតិស្អាត មានពន្លឺរស្មី ត្រចះត្រចង់ ចែងចាំងភ្លឺថ្លា ប៉ុន្តែប្រែ ក្លាយទៅជាមន្ទិល សៅហ្មងទៅវិញ ដោយអាស្រ័យហេតុ គឺកិលេស ដែល ទើបកើតលាយលំជាថ្មីធ្វើអោយសៅហ្មង អាប់ពន្លឺខុសប្រក្រតីដើមទៅវិញ ។

**បុណ្យមាន ៣ ស្ថាន គឺ**

១- ពោលដោយឫសគល់របស់បុណ្យ បានដល់កុសលមូល៣ គឺ អលោភៈ អទោសៈ អមោហៈ។ គេលះ លោភៈ ដោយអោយទាន ។ លះទោសៈ ដោយរក្សាសីល លះមោហៈ ដោយចម្រើន ភាវនា (អប់រំ បញ្ញា) អោយភ្លឺថ្លា ហៅថា «បុណ្យ ជាហេតុ» ។

២- ពោលតាមវត្ថុដែលគេសម្រេចទៅជាពិធីបុណ្យ នីមួយៗ មាន១០ យ៉ាង ហៅបុញ្ញកិរិយាវត្ថុ ១០ គឺ :

ក- ទានមយៈ បុណ្យសម្រេចដោយការអោយទាន

ខ- សីលមយៈ បុណ្យសម្រេចដោយការក្សាសីល

គ- ភាវនាមយៈ បុណ្យសម្រេចដោយការចម្រើនកុសល

ឃ- អបចាយនមយៈ បុណ្យសម្រេចដោយការគោរពក្រែងចាស់ ព្រឹទ្ធា ចារ្យ គ្រូកូលរៀមច្បង

ង- បត្តិទានមយៈ បុណ្យសំរេចដោយចែកចំណែកបុណ្យដល់គ្នា

ច- បត្តានុមោទនាមយៈ បុណ្យសម្រេចដោយត្រេកអរចំពោះចំ ណែក បុណ្យដែលអ្នកដទៃអោយ

ឆ- វេយ្យាវច្ចមយៈ បុណ្យសម្រេចដោយខ្វល់ខ្វាយ ជួយខ្នះខ្នែង ក្នុងពិធីបុណ្យគេ

ជ- ធម្មស្សវនមយៈ បុណ្យសំរេចដោយការស្តាប់ធម៌



www.budinst.gov.kh www.elibraryofcambodia.org

ឈ- ធម្មទេសនាមយៈ បុណ្យសម្រេចដោយសម្តែងធម៌

ញ- ទិដ្ឋុជុកម្មមយៈ បុណ្យសម្រេចដោយធ្វើទិដ្ឋិអោយត្រង់ (សម្មាទិដ្ឋិ)។

៣- ពោលតាមផលរបស់បុណ្យនិមួយៗ ការសន្សំបុណ្យគឺការរក្សា ទុកនូវអារម្មណ៍ជាបុណ្យ ជាប់ជានិច្ច នាំមកនូវសេចក្តីសុខត្រជាក់ច្រជុំ ទូលំទូលាយ មិនមានក្តៅក្រហាយ អន្ទះអន្ទែង រួមមកហៅថាបុណ្យ ជាផល។

## ៥- អ្វីខ្លះជាអានិសង្សរបស់បុណ្យ ?

ចិត្តត្រេកអរីករាយ ទូលំទូលាយជ្រៅលជ្រៅ ធំធេង គ្មានចង្អៀតចង្អល់ ដូចមហាសាគរ មុនធ្វើ កំពុងធ្វើ និងធ្វើរួចហើយ ដោយបាន សម្រេចផល ជាទីពេញចិត្តទទួលបាននូវ បុញ្ញសម្បទាគ្រប់យ៉ាង ទាំងក្នុងលោកនេះ និងលោកខាងមុខ ព្រមទាំងឧបត្ថម្ភ អារម្មណ៍ជាបុណ្យ ជាប់ជានិច្ចទៀតផង នេះហៅថាអានិសង្សបុណ្យ ។

## សម្បទាបុណ្យមាន ៥ យ៉ាងគឺ

១- ញ្ញាតិសម្បទា សម្បូរដោយញាតិ

២- អារោគសម្បទា បរិបូណ៌ដោយសុខភាព

៣- ភោគសម្បទា បរិបូណ៌ដោយទ្រព្យ

៤- សីលសម្បទា បរិបូណ៌ដោយសីលធម៌

៥- ទិដ្ឋសម្បទា បរិបូណ៌ដោយទិដ្ឋិ គឺប្រាជ្ញាយល់ឃើញត្រូវ។

លើកឡើងជាឧទាហរណ៍បុគ្គលិកលក្ខណៈ នៃបុគ្គលដែលប្រកបដោយបុញ្ញសម្បទា គឺនាងវិសាខា មហាឧបាសិកា ជាស្ត្រីប្រកបដោយបុញ្ញ សម្បទា ៥ យ៉ាងគឺ

១- ញ្ញាតិសម្បទា បរិបូណ៌ដោយញាតិ គឺនាងមានកូន ២០ ចៅ ៤០០ ចៅទួត ៨០០០ បូករួមត្រូវជា ៨៤២០ នាក់។



www.budinst.gov.kh www.elibraryofcambodia.org

២- អារោគ្យសម្បទា បរិបូណ៌ដោយមិនមានរោគ គឺទាំង៨៤២០ នាក់ រួមទាំងខ្លួននាងផង មានសុខភាពល្អដូចគ្នា នាងមានអាយុ ១២០ឆ្នាំ។

៣- គោភសម្បទា បរិបូណ៌ដោយទ្រព្យ គឺក្នុងសម័យពុទ្ធកាល អ្នកដែលមានទ្រព្យភោគច្រើនជាងគេ ព្រមទាំងមានសទ្ធាបរិច្ចាគធ្វើទានផង ផ្នែកបុរសគឺអនាថបណ្ឌិតសេដ្ឋី ផ្នែកស្ត្រីគឺនាងវិសាខា។

៤- សីលសម្បទា បរិបូណ៌ដោយសីល គឺនាងវិសាខា បានសម្រេចសោតាបត្តិផល តាំងពីក្មេងអាយុ ៧ឆ្នាំ សីលរបស់នាង ជាមុច្ចេទប្ប ហានៈ។

៥- ទិដ្ឋិសម្បទា បរិបូណ៌ដោយប្រាជ្ញា ជាសមាទិដ្ឋិ ទោះបីត្រកូលខាងប្តីរបស់នាងជាមិច្ឆាទិដ្ឋិ ក៏នាងនៅជាសមាទិដ្ឋិដដែល។

## ធ្វើបុណ្យដើម្បីអ្វី ?

តាមលទ្ធិព្រះពុទ្ធសាសនា ធ្វើដើម្បីបំភ្លេចអារម្មណ៍បាបចាស់ ដែលបានធ្វើហើយពីមុនមកទាំងប៉ុន្មានអោយជ្រះស្រលះ លែងរសេសរសាម ស្រមើលស្រមៃ បញ្ឈប់រាំងស្ទាក់ចិត្តលែងត្រេកត្រអាល រីករាយចំពោះ បាបថ្មីទៅទៀត កាសចិត្តអោយឃ្លាតឆ្ងាយចាកបាប រួចហើយយកឱកាស ទំនេរធ្វើបុណ្យជំនួសវិញភ្លាម ដើម្បីដុសខាត់ជម្រះសន្តានចិត្ត អោយអស់មន្ទិលសៅហ្មងដោយពិធីអោយទាន សមាទានសីល ចម្រើនមេត្តា ភាវនាជាដើម អោយទៅជាចិត្តស្អាត មានពន្លឺរស្មី ត្រចះត្រចង់ប្រក្រតីឡើងវិញ (បកតិមនោ) តែប៉ុណ្ណោះ ពុំមែនជាពិធីលាងបាប ដូច សាសនាដទៃឡើយ ។

## ៧- ផ្លូវចិត្តជាបុណ្យ គេកត់សំគាល់យ៉ាងណា ?

នៅពេលណាចិត្តអស់លែងមានទោស មានអភិជ្ឈា និងទោមនស្សជាដើម ប្រទូស្តហើយជាចិត្ត រងថ្លាស្អាតបរិសុទ្ធ ដូចប្រក្រតីដើម (ភវង្គៈ) ដូចព្រះពុទ្ធដីកាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចិត្តនេះកាលដើមឡើយ មានពន្លឺរស្មីភ្លឺថ្លាណាស់ ក៏ប៉ុន្តែលុះត្រូវឧបក្កិលេសទាំងឡាយ មាន អភិជ្ឈាវិសមលោភៈ ជាដើម ជារបស់ថ្មី កើតលាយលំ ទើបធ្វើអោយសៅហ្មង។ នៅពេល



www.budinst.gov.kh www.elibraryofcambodia.org

ណាគេធ្វើអោយស្អាតភ្លឺថ្លាឡើងវិញ ពេលនេះហើយគេ ត្រូវសំគាល់ចិត្តនោះជាបុណ្យ។

តើព្រះពុទ្ធដីកាត្រាស់ថា បុរសប្រុសស្រី គប្បីប្រញាប់ប្រញាល់ ធ្វើកល្យាណកម្ម (បុណ្យ) ទាំងឡាយ ន័យនេះទ្រង់សំដៅលើអ្វី ?

ការដែលទ្រង់ណែនា អោយប្រញាប់ប្រញាល់ធ្វើបុណ្យ គឺសំដៅលើន័យទាំង ៤យ៉ាង :

១- នាំអោយហាមឃាត់ចិត្ត ឈប់ត្រេកត្រអាល ក្នុងបាបបាន ភ្លាមៗ

២- នាំអោយបំភ្លេចច្រោល នូវអារម្មណ៍ជាបាបចាស់អស់រលីង ភ្លាមៗ

៣- នាំអោយបិទផ្លូវបាបថ្មី ដែលពុំទាន់មកដល់មិនអោយចូលមកតាមកាយទ្វារ វចីទ្វារ មនោទ្វារ បានភ្លាមៗ

៤- នាំអោយឱកាស សន្សំបុណ្យ កុសលថ្មីៗ ជាជំនួសវិញបានពេញបរិបូណ៌ភ្លាមៗ ដែរ។

**ចប់**


www.budinst.gov.kh www.elibraryofcambodia.org

## ប្រវត្តិធង់សាសនា ៦ ពណ៌

(ពាក្យ ៧)

- ពណ៌ខៀវ កាលឆ្លៀលព្រះនេត្រា អោយឥន្ទព្រាហ្មណ៍ កាលជាស្តេច នាមស្រីពិរាស្ត្រ ចង់សម្រេច សពិជ្ជ ជាស្តេចសាស្តាចារ្យ។

- ពណ៌លឿង កាលអារសាច់ធ្វើមាស បិទលនអង្គព្រះពុទ្ធបដិមា ព្រះឥន្ទជាជារចនា ស្រែកសាធុការ ពេញផែនដី។

- ក្រហមជាពណ៌ឈាមបេះដូង ឆ្លៀលពីដើមទ្រូង ដោយឃ្មាតខ្ចី បិទពិសពស់ខាំព្រះជននី គង់រស់ជីវិតជាតេរ្បីយទៅ។

- ពណ៌អោយទានដីរ - ស មង្គលបវរមាសឆ្អិនឆ្អៅ ត្រូវរាស្ត្រ បណ្តេញអោយចេញទៅ គង់នៅខាងក្រៅព្រះនគរ។

- ហង្សបាទលោហិត និងមំសំ អារសាច់ខ្លួនតាំងជួសមាតា កាលយក្សវាចាប់បរិភោគក្តា ជីវិតមាតារសិវិញខ្ចី ។

- ពណ៌ផ្លេករាយកាលប្រាជ្ញាទន្សាយ អោយទានពុំស្តាយជីវិតក្តី លោតចូលភ្នក់ភ្លើង ពុំថាអ្វី អោយចំណីដល់ ឥន្ទព្រាហ្មណ៍ ។



www.budinst.gov.kh www.elibraryofcambodia.org

ថ្វាយគ្រឿងសក្ការៈ ជំនួសទៀន ធូប គ្រឿងក្រអូប

**សីសំ មេ បទុមំ កត្វា ទីបញ្ច នយនទ្វយំ**

**វចសា ធូបការេន មនសា ច សុគន្ធិកំ ៗ**

ខ្ញុំសូមឱនសិរសា ធ្វើជាផ្កាឈូកឧត្តម និងភ្នែកទាំងពីរ ផ្សំទុកជាគ្រឿងប្រទីបថ្លៃ ព្រមទាំងសុវាចា ខ្ញុំសូមធ្វើជាធូបប្រពៃ ចិត្តនឹកព្រះរ័ត្នត្រៃយ៍ ទុកជាក្លិនក្រអូបហោង ។

ឧទ្ទិសផ្សព្វផ្សាយ ផលទាន

**ឥទំ វោ ញាតីនំ ហោតុ**

**សុខិតា ហោន្តុ ញាតយោ ៗ**

ផលទានយើងទាំងឡាយ សូមផ្សព្វផ្សាយដល់ញាតិមិត្ត
ទៅកើតទីឆ្ងាយជិត មានវិបត្តិយ៉ាងណាក្តី
សូមអោយរួចរំដោះ ចាកទុក្ខទោសគ្រោះចង្រៃ
បានសុខរៀងរាល់ថ្ងៃ សមដូចក្តីឧទ្ទិសហោង ។

www.budinst.gov.kh www.elibraryofcambodia.org

021670
$ 0.20
www.budinst.gov.kh www.elibraryofcambodia.org